# កិច្ចតែងការបង្រៀន

- កាលបរិច្ឆេទ ៖ ថ្ងៃសុក្រ ទី២២ ខែ សីហា ឆ្នាំ២០២៥
- មុខវិជ្ជា ៖ ភាសាខ្មែរ
- ប្រធានបទ ៖ សមត្ថភាពគូស និងសរសេរ
- សកម្មភាព ៖ ល្បែង
- ចំណងជើង ៖ ផ្គុំរូបភាព( សម្ភារៈផ្សេងៗ )
- កម្រិតថ្នាក់ ៖ មធ្យម
- រយៈពេល ៖ ៣០នាទី

## I. វត្ថុបំណង

- វិជ្ជាសម្បទា ៖ កុមាប្រាប់បានពីរបៀបផ្គុំរូបភាព( សម្ភារៈផ្សេងៗ )ដែលអ្នកគ្រូយកមកបង្រៀន បានត្រឹមត្រូវ តាម រយៈការណែនាំរបស់គ្រូ។
- បំណិនសម្បទា ៖ កុមារកំណត់បានពីរបៀបផ្គុំរូបភាព( សម្ភារៈផ្សេងៗ )ដែលអ្នកគ្រូយកមកបង្រៀន បានត្រឹមត្រូវ តាម រយៈ ការអនុវត្តផ្ទាល់។
- ចរិយាសម្បទា ៖ បណ្តុះស្មារតីកុមារឲ្យមានភាពក្លាហាន ឈ្លាសវៃ ចេះសហការគ្នា មានបម្រុងប្រយ័ត្ន និង មានភាពសប្បាយរីករាយ។

## II. សម្ភារឧបទ្ទេស ៖

- សម្រាប់គ្រូ ៖ ក្រដាសរូបភាព និងបំណែករូបភាព
- សម្រាប់កុមារ ៖ ក្រដាសរូបភាព និងបំណែករូបភាព
- ការរៀបចំកុមារ ៖ អង្គុយជា៣ក្រុម

## III. ដំណើរការបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារបង្រៀន | សកម្មភាពកុមារ |
|---|---|---|
| | ❖ ជំហានទី១ | |
| | *លំនឹងថ្នាក់ | |
| -តើកូនៗមកជុំគ្នាហើយឬនៅ ? អោយមេក្រុមពិនិត្យសមាជិកក្នុងក្រុម | -ពិនិត្យវត្តមាន | -ស្តាប់និងឆ្លើយ |
| -កូនដាក់ដៃលើតុអ្នកគ្រូពិនិត្យក្រចក | -ពិនិត្យអនាមយ័ | -ដាក់ដៃលើតុ |
| -កូនមើលកៅអីកូនអង្គុយមានរបៀបហើយឬនៅ ? | -សណ្តាប់ធ្នាប់ | -មានរបៀបហើយ |
| -កូនក្រោកឈរឡើងច្រៀងចម្រៀងបទ មកទីនេះ | -ប្រមូលអារម្មណ៍ | -ច្រៀង |
| | ❖ ជំហានទី២ | |
| | *រំលឹកមេរៀនចាស់ | |
| -តើពីថ្ងៃមុនអ្នកគ្រូបានបង្រៀនមេរៀនភាសាខ្មែរអ្វីដល់កូន ? | -ភាសាខ្មែរៈល្បែងផ្គុំស្លាកសញ្ញាចរាចរណ៍ | -ឆ្លើយប្រាប់អ្នកគ្រូ |
| | *ទំនាក់ទំនងមេរៀនថ្មី | |
| -តើនៅពេលមកសាលាកូនៗយកអ្វីមកខ្លះកូន ? | -កាបូប សៀវភៅ ប៊ិច ខ្មៅដៃ ក្តារ... | -ឆ្លើយ |

| | | |
|---|---|---|
| | ❖ **ជំហានទី៣** | |
| | *មេរៀនថ្មី | |
| -ថ្ងៃនេះអ្នកគ្រូនិងមានមេរៀនថ្មីមកបង្រៀនកូនគឺភាសាខ្មែរ ល្បែងផ្គុំរូបភាព( សម្ភារៈផ្សេងៗ) | -ប្រាប់ចំណងជើង៖ភាសាខ្មែរ ៖ ល្បែងផ្គុំរូបភាព( សម្ភារៈផ្សេងៗ) | -ស្តាប់ |
| -កូនអានតាមអ្នកគ្រូទាំងអស់គ្នា | -អានចំណងជើងតាមអ្នកគ្រូ | -អានតាម |
| -គ្រូបង្ហាញសម្ភារហើយបិទលើក្តាខៀនឲ្យកុមារសង្កេត | -បង្ហាញសម្ភារ<br>  | -មើលនិងសង្កេត |
| -ដំបូងគឺកូនត្រូវយកផ្ទាំងរូបគំរូដែលមានប្រអប់នៅខាងក្រោមសម្រាប់ផ្គុំបំណែករូបភាពមកដាក់ពីមុខខ្លួនសិនរួចចាំស្វែងរកបំណែករូបភាពមកផ្គុំចូលគ្នាធ្វើយ៉ាងណាឲ្យដូចរូបគម្រូខាងលើជាការស្រេច ពេលផ្គុំរូបបានត្រឹមត្រូវហើយកូនៗត្រូវនាំគ្នាឱបដៃហើយស្រែកប្រាប់អ្នកគ្រូថាក្រុមកូនរួចរាល់ហើយ និងនាំគ្នាអង្គុយឲ្យស្ងៀមចាំអ្នកគ្រូដើរ<br>ពិនិត្យសិនណា | -ណែនាំពីរបៀបអនុវត្តន៍ | -ស្តាប់ មើល |
| -កូនណាអាចឡើងមកធ្វើសាកល្បងឲ្យមិត្តយើងមើលបានកូន | -អនុវត្តន៍សាកល្បង | -អនុវត្តន៍សាកល្បង |
| -អញ្ចឹងអ្នកគ្រូចែកកូនជា ៣ក្រុម ហើយកូនៗចូលតាមក្រុមអង្គុយឲ្យមានរបៀបរៀបរយណាកូន | -ចែកក្រុម | -ចូលក្រុម |
| -ឥឡូវកូនអង្គុយមានរបៀបល្អហើយពេលនេះអ្នកគ្រូចែកសម្ភារៈឲ្យ | -ចែកសម្ភារៈ | -ទទួល |
| -កូនៗចាប់ផ្តើមបានហើយ | -អនុវត្តន៍ | -អនុវត្តន៍ |
| -គ្រូដើរសម្របសម្រួលនិងពិនិត្យមើលក្រុមណាដែលធ្វើមិនទាន់បានល្អ | -សម្របសម្រួល | -ស្តាប់ |
| -គ្រូនិងកុមារផ្ទៀងផ្ទាត់លទ្ធផលនិងវាយតម្លៃ | -ផ្ទៀងផ្ទាត់លទ្ធផលនិងវាយតម្លៃ | -ផ្ទៀងផ្ទាត់លទ្ធផល |
| | ❖ **ជំហានទី៤** | |
| | *ពង្រឹងចំណេះដឹង | |
| -តើអំបាញ់មិញអ្នកគ្រូបានបង្រៀនមេរៀនភាសាខ្មែរអ្វីដល់កូន? | -ភាសាខ្មែរ៖ល្បែងផ្គុំរូបភាព( សម្ភារៈផ្សេងៗ) | -ឆ្លើយ |
| -កូនណាអាចធ្វើឡើងវិញបានកូន | -អនុវត្តន៍ឡើងវិញ១ឬ២នាក់ | -អនុវត្តន៍ឡើងវិញ |

| | | |
|---|---|---|
| -ថ្ងៃនេះអ្នកគ្រូសប្បាយចិត្តណាស់ដែលកូនយកចិត្តទុកដាក់ក្នុងការរៀនសូត្រ<br>-ពេលកូនត្រលប់ទៅផ្ទះវិញកុំភ្លេចប្រាប់ប៉ាម៉ាក់ថាថ្ងៃនេះអ្នកគ្រូបានបង្រៀនភាសាខ្មែរ ល្បែងផ្គុំរូបភាព( សម្ភារៈផ្សេងៗ)និងត្រូវស្តាប់បង្គាប់ប៉ាម៉ាក់ផងណាកូន។ | ❖ ជំហានទី៥<br>*បណ្តាំផ្ញើ<br>-ការលើកទឹកចិត្តនិងសរសើរកុមារ<br><br>-បណ្តាំផ្ញើ | -ស្តាប់<br><br>-ស្តាប់ |

**មតិយោបល់**.................................. ថ្ងៃ ខែ ឆ្នាំ ព.ស២៥៦....

.......................................................... ត្រូវនិងថ្ងៃទី ខែ ឆ្នាំ២០២....

.......................................................... គ្រូប្រចាំថ្នាក់

..........................................................

..........................................................

ឈាន សុខមឿន

បានពិនិត្យត្រឹមត្រូវ

ថ្ងៃ ខែ ឆ្នាំ ព.ស២៥៦....

ត្រូវនឹងថ្ងៃទី ខែ ឆ្នាំ២០២......

នាយិកាសាលា